## ថ្ងៃផុតកំណត់ត្រូវបានបន្តសម្រាប់ការជ្រើសរើសកម្មវិធីសិក្សា

បុគ្គលិកក្រសួងអប់រំឡុងប៊ីច LBUSD បានធ្វើការយ៉ាងមមារញឹកដើម្បីរៀបចំគ្រោងកម្មវិធីសិក្សាជាច្រើនជំរើសដើម្បីសម្រប ទៅតាមសេចក្តីចាំបាច់របស់សិស្សនិងគ្រួសារនៅក្នុងពេលរាតត្បាតនេះ។ ដើម្បីរៀបចំគ្រោងសម្រាប់ឆ្នាំសិក្សាថ្មី ហើយនិង ដើម្បីអនុញ្ញាតឱ្យមានការបត់បែនបានក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរដែលអាចតម្រូវឱ្យយើងធ្វើ យោងទៅតាមឱវាទនិង ការណែនាំពីមន្ត្រីសុខភាពរបស់រដ្ឋ ខោនធី និងក្រុង ជាថ្មីៗកន្លងទៅនេះយើងបានធ្វើការស្ទង់មតិមួយទៅឱ្យគ្រួសារសិស្សស្តី អំពីចំណង់ចំណូលចិត្តរបស់ពួកគាត់លើកម្មវិធីសិក្សាសម្រាប់ឆ្នាំ២០២០-២០២១។ ថ្ងៃផុតកំណត់សម្រាប់ឆ្លើយតបការស្ទង់ មតិនេះត្រូវបានបន្តទៅដល់ថ្ងៃទី១៨ខែសីហា។ សូមបញ្ជាក់ថា សិស្សទាំងអស់ដែលបានចុះឈ្មោះចូលរៀនរួចហើយនឹងនៅ តែមានឈ្មោះរៀននៅសាលានោះដដែល។ ការឆ្លើយតបនៅក្នុងការស្ទង់មតិនេះពុំមានប៉ះពាល់ដល់សាលារៀនរបស់អ្នក និងកម្មវិធីពិសេសឬកម្មវិធីសិក្សារបស់អ្នកឡើយ។ ការស្ទង់មតិនេះគឺគ្រាន់តែឱ្យយើងស្វែងយល់ដឹងនូវជំរើសរបស់អ្នកស្តីអំពី ពហុជំរើសសម្រាប់សិស្សប៉ុណ្ណោះ ដើម្បីឱ្យយើងរៀបចំគ្រោងគ្រូបង្រៀននិងកាលវិភាគសិក្សាមេ។ លោកអ្នកអាចចូលទៅធ្វើ ការស្ទង់មតិនេះនៅក្នុង ParentVUE ដែលស្ថិតនៅក្នុងផ្នែក School of Choice ហើយបន្ទាប់មកនៅក្នុង "Parents Click to Choose a Program for 2010-2021" ។ បើសិនជាលោកអ្នកបានឆ្លើយតបនឹងការស្ទង់មតិតាមរបៀបនេះរួចហើយ សូម លោកអ្នកមិនបាច់អានសេចក្តីជូនដំណឹងនេះទេ។ ក៏ប៉ុន្តែ បើលោកអ្នកចង់ផ្លាស់ប្តូរជំរើសរបស់លោកអ្នក លោកអ្នកអាចធ្វើ ការផ្លាស់ប្តូរបានរហូតទៅដល់ថ្ងៃទី១៨ខែសីហាដែលជាថ្ងៃផុតកំណត់ដែលបានបន្ត។

របៀបដែលងាយស្រួលជាងគេក្នុងការធ្វើការជ្រើសរើសគឺតាមរយៈកម្មវិធីក្នុងទូរស័ព្ទចល័ត ParentVUE mobile app ។ មានគ្រួសារខ្លះបានជួបប្រទះនឹងបញ្ហាបច្ចេកទេសឬភាពយឺតយ៉ាវពេលប្រើកុំព្យូទ័រដោយសារតែមានគេចូលប្រើតាមប្រព័ន្ធ នេះច្រើនពេក។

ចំពោះគ្រួសារណាដែលមិនបានឆ្លើយតបទៅនឹងការស្ទង់មតិនេះទេ ជំរើសស្វ័យប្រវត្តគឺឱ្យកូនគាត់ទៅរៀននៅសាលាដូច ធម្មតា(ថ្នាក់មត្តេយ្យ-ទី៥)ឬដោយប្រភេទពាក់កណ្តាលនៅសាលានិងពាក់កណ្តាលនៅផ្ទះ(ថ្នាក់ទី៦-១២) នៅពេលណាធ្វើ ទៅបានដោយសុវត្ថិភាព។

### ជាសង្ខេប

- ការស្ទង់មតិអំពីការជ្រើសរើសកម្មវិធីសិក្សាគឺមានតាមរយៈគណនី ParentVUE នៅក្នុងផ្នែក "School of Choice"
- ការជ្រើសរើសនេះអាចកែផ្លាស់ប្តូរប៉ុន្មានដងក៏បានដែររហូតទៅដល់ថ្ងៃផុតកំណត់។
- សិស្សទាំងអស់នឹងចាប់ផ្តើមរៀនតាមអនឡាញ រហូតទាល់តែមន្ត្រីសុខភាពរបស់រដ្ឋ ខោនធី និងក្រុង បានពិភាក្សា ជាមួយក្រសួងអប់រំហើយយល់ឃើញថាសិស្សអាចទៅរៀននៅសាលាវិញបានដោយសុវត្ថិភាព។

## សំណួរនិងចម្លើយដែលបានសួរញឹកញាប់ជាងគេអំពីការជ្រើសរើសកម្មវិធីសិក្សា

### ហេតុអ្វីបានជាការជ្រើសរើសនេះតម្រូវឱ្យរៀននៅក្នុងកម្មវិធីដែលបានជ្រើសរើសពេញមួយឆ្នាំ?

ការតម្រូវឱ្យរៀនក្នុងកម្មវិធីពេញមួយឆ្នាំគឺដើម្បីកាត់បន្ថយការរអាក់ខានក្នុងការរៀនសូត្ររបស់សិស្សនៅពេលដែលយើងអាចវិលត្រឡប់ទៅសាលារៀនវិញបានដោយសុវត្ថិភាព។ ការដឹងជាមុននូវចំណង់ចំណូលចិត្តរបស់គ្រួសារវាជួយយើងក្នុងការបង្កើតកាលវិភាគសិក្សាមេដែលនឹងជួយកាត់បន្ថយការរំខានដល់សិស្ស និងកាត់បន្ថយការផ្លាស់ប្តូរគ្រូបង្រៀននិងមុខវិជ្ជាសិក្សានៅកណ្តាលឆ្នាំ។ ដោយធ្វើរបៀបនេះសិស្សនឹងមានតារាងវេលាស្តេរ (ឧ. គ្រូនិងមុខវិជ្ជាដដែល)ពេញមួយឆ្នាំ។

### តើមានអ្វីនឹងកើតឡើងបើខ្ញុំដូរចិត្តនៅក្នុងឆមាស ឬនៅពេលណាមួយបន្ទាប់ពីសិស្សចូលទៅរៀននៅសាលាវិញ?

យើងនឹងមាននីតិវិធីមួយរួចស្រេចដែលមាតាបិតាអាចសុំដូរជំរើសសម្រាប់ឱ្យកូនគាត់នៅថ្ងៃក្រោយ។ ក៏ប៉ុន្តែ ការផ្លាស់ប្តូរកម្មវិធីនៅថ្ងៃមុខអាចតម្រូវឱ្យមានការផ្លាស់ប្តូរគ្រូបង្រៀនដែរ។ ឧទាហរណ៍ៈ បើសិនជាថ្នាក់មួយមានសិស្ស៣០នាក់ហើយទាំងអស់គ្នាបានជ្រើសរើសកម្មវិធីរៀនតាមអនឡាញ អញ្ចឹងយើងនឹងដាក់សិស្សទាំងនោះឱ្យរៀនជាមួយគ្រូ "ក" នៅដើមឆ្នាំសិក្សា។ ក៏ប៉ុន្តែ បើទៅថ្ងៃមុខ មានសិស្ស១០នាក់ក្នុងថ្នាក់នោះដូរចិត្តហើយសុំទៅរៀនជាមួយគ្រូផ្ទាល់នៅសាលាវិញ សិស្សទាំងនោះនឹងត្រូវដាក់ឱ្យរៀនជាមួយគ្រូ "ខ" វិញនៅសាលា  ខណៈដែលសិស្សរួមថ្នាក់២០នាក់ទៀតនឹងនៅរៀនតាម អនឡាញដដែលជាមួយគ្រូ "ក" ។

### តើការជ្រើសរើសរបស់ខ្ញុំនឹងតម្រូវឱ្យមានការដកកូនខ្ញុំចេញពីសាលារៀនឬកម្មវិធីដែលខ្ញុំបានជ្រើសរើសនោះដែរឬទេ?

ទេ ការជ្រើសរើសនេះប៉ះពាល់តែលើរបៀបដែលសិស្សទទួលការបង្ហាត់បង្រៀនសម្រាប់ឆ្នាំសិក្សា២០២០-២០២១នេះទេ។ វាមិនប៉ះពាល់ដល់កន្លែងរៀនឬកម្មវិធីដែលបានជ្រើសរើសនោះទេ។ ឧទាហរណ៍ៈ បើសិនអ្នកជាសិស្ស Poly PACE ហើយអ្នកបានជ្រើសរើសកម្មវិធីរៀនតាមអនឡាញឬ APEX ពេញមួយឆ្នាំ អ្នកនឹងនៅតែជាសិស្ស Poly PACE ដដែលហើយនឹងមិនបាត់បង់កន្លែងរបស់អ្នកនៅក្នុងកម្មវិធីទេ។

### តើថ្នាក់ GATE (ថ្នាក់សម្រាប់សិស្សមានកោសល្យនិងពូកែ) ដែលរៀនតាមអនឡាញខុសគ្នានឹងថ្នាក់ដទៃទៀតដូចម្តេចខ្លះ?

ថ្នាក់ GATE នឹងទទួលការគាំទ្រតាមរយៈគំរូជាមួយគ្រូផ្ទាល់និងតាមអនឡាញ។ គ្រូដែលបង្រៀនតាមគំរូទាំងពីរនេះនឹងដាក់យុទ្ធសាស្ត្រដើម្បីពន្លឿនការរៀនសូត្ររបស់សិស្សហើយសម្របតម្រូវទៅតាមសេចក្តីត្រូវការរបស់សិស្សដែលរៀនពូកែ។

**តើអ្នកណានឹងបង្រៀនតាមអនឡាញ?**

គ្រប់ថ្នាក់អនឡាញនិងថ្នាក់រៀនដោយឯករាជ្យ (APEX) ទាំងអស់នឹងត្រូវបង្រៀនដោយគ្រូបង្រៀនរបស់ក្រសួងអប់រំឡុងប៊ីច ដែលមានគរុកោសល្យនិងមានសមត្ថភាពខ្ពស់។

**តើកម្មវិធីរៀនដោយឯករាជ្យ APEX ជាកម្មវិធីរៀននៅផ្ទះ ហូមស្កូលឬ? ហើយអ្នកណាជាអ្នកបង្រៀន APEX នេះ?**

APEX ជាគំរូរៀនដោយឯករាជ្យសម្រាប់ឆ្នាំសិក្សា២០២០-២០២១។ សិស្សដែលជ្រើសរើសគំរូនេះនឹងត្រូវគាំទ្រដោយ និងមានទំនាក់ទំនងជារឿយៗជាមួយគ្រូបង្រៀនដែលមានគរុកោសល្យ។ ខណៈដែលការគាំទ្រពីឪពុកម្ដាយមានសារៈសំខាន់ដល់រាល់ប្រភេទនៃកម្មវិធីសិក្សា កម្មវិធីនេះគឺបង្រៀនដោយគ្រូបង្រៀនរបស់ LBUSD ។

**តើអ្នកដោះស្រាយបញ្ហាដែលសិស្សចំណាយពេលច្រើនពេកនៅពីមុខអេក្រង់កុំព្យូទ័រដោយរបៀបណា?**

នៅក្នុងការរៀនតាមអនឡាញ យើងបានហ្វឹកហ្វឺនគ្រូបង្រៀនឱ្យប្រើពេលបង្រៀនតាមអនឡាញសម្រាប់សកម្មភាពសកម្ម ដែលមានរួមទាំងកិច្ចការមុខអេក្រង់ កិច្ចការធ្វើខ្លួនឯង(ដោយមានគ្រូ) ហើយនិងពេលម៉ោងសម្រាក។ *ឧទាហរណ៍ៈ រៀន មុខវិជ្ជាគណិតសាស្ត្រតាមអនឡាញចំនួន៦០នាទីដែលមានរួមទាំងពេលតាមសង្កេតមើលគ្រូ ធ្វើកិច្ចការដោយខ្លួនឯងក្នុងសៀវភៅមេរៀន ពិភាក្សាជាមួយសិស្សរួមថ្នាក់ដើម្បីដោះស្រាយចំណោទ ហើយទទួលមតិត្រឡប់ពីគ្រូ។*

**បើខ្ញុំជ្រើសរើសគំរូសិក្សាណាមួយ តើខ្ញុំអាចដូរវិញនៅថ្ងៃក្រោយបានទេ?**

បើអ្នកដូរចិត្តវិញក្រោយពេលដែលសាលាបានចាប់ផ្ដើមហើយ លទ្ធភាពរបស់សាលាក្នុងការធ្វើតាមសំណូមពរនឹងអាស្រ័យទៅលើកន្លែងដែលមាន នៅក្នុងគំរូសិក្សានោះ។ ថែមពីនោះទៀត ការផ្លាស់ប្ដូរគំរូសិក្សានឹងតម្រូវឱ្យមានថ្នាក់ថ្មីនិងគ្រូបង្រៀនថ្មីនៅកំរិតសាលាបឋមសិក្សា ហើយនិងតារាងវេលារៀនថ្មីមួយផងដែរ ហើយបើនៅកំរិតសាលាវិទ្យាល័យ អាចនឹងមានគ្រូថ្មី

**តើវាអាចទេដែលកូនខ្ញុំនឹងរៀនជាមួយគ្រូដែលមិនមែនជាគ្រូនៅសាលាកូនខ្ញុំ?**

យើងនឹងប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការដាក់សិស្សឱ្យរៀនជាមួយគ្រូដែលបង្រៀននៅសាលាដែលសិស្សទៅរៀន។ ក្នុងកាលៈទេសៈខ្លះៗ ការរៀនតាមអនឡាញនិងការរៀនដោយឯករាជ្យអាចត្រូវបង្រៀនដោយគ្រូពីសាលាផ្សេងទៀត ដែលមានតារាងវេលាបង្រៀនដូចគ្នា។ សាលារៀនដែលសិស្សទៅរៀនគឺនៅដដែល ពុំមានផ្លាស់ប្ដូរទេ។

**តើមុខវិជ្ជាកាយវប្បកម្ម(ហាត់ប្រាណ)និងមុខវិជ្ជាជំរើសតាមចំណូលចិត្ត(អ៊ីឡិកទីវ)នឹងមានបង្រៀនតាមអនឡាញទេ?**

មុខវិជ្ជាកាយវប្បកម្មនឹងមានបង្រៀនតាមអនឡាញ។ មុខវិជ្ជាអ៊ីឡិកទិវក៏មានបង្រៀនតាមអនឡាញដែរ ប៉ុន្តែអាចមានតិចអាស្រ័យទៅលើចំនួនសិស្សដែលជ្រើសរើសការរៀនតាមអនឡាញទាំងស្រុង។ មុខវិជ្ជាអ៊ីឡិកទិវផ្សេងទៀតអាចមានផ្តល់ឱ្យនៅសាលាមហាវិទ្យាល័យ LBCC ឬតាមការរៀនដោយឯករាជ្យ APEX

**តើការរៀនតាមអនឡាញលើកនេះនឹងមានភាពខុសគ្នាពីការរៀនតាមអនឡាញកាលពីនិទាឃរដូវកន្លងទៅនេះដោយរបៀបណា?**

ការរៀនតាមអនឡាញលើកនេះនឹងមានភាពខុសគ្នាយ៉ាងច្រើនពីការរៀនតាមអនឡាញដែលសិស្សបានមានការពិសោធន៍កាលពីនិទាឃរដូវកន្លងមកនេះ។ ទីមួយ គំរូសិក្សានឹងចម្លងតាមការសិក្សាធម្មតាផ្ទាល់ជាមួយគ្រូក្នុងថ្នាក់ ដោយមានការបង្រៀនតាមអនឡាញពេញម៉ោងក្នុងមួយថ្ងៃ។ សិស្សនឹងរៀនតាមអនឡាញក្នុងមេរៀនដែលរួមបញ្ចូលពួកគេជាសកម្ម។ ការបង្រៀននឹងមានការផ្លាស់ប្តូរពីការគ្រាន់តែដាក់កិច្ចការឱ្យសិស្សធ្វើទៅការចូលរួមជាសកម្មនៅក្នុងការបង្រៀនផ្ទាល់និងមេរៀនដែលតម្រូវឱ្យមានការរុករកស្វែងយល់ ដើម្បីពង្រឹងដល់ការគិតរិះរក ការសហការគ្នា និងការពិភាក្សាគ្នា។ ហើយទីបំផុតសិស្សនឹងបានទទួលមតិត្រឡប់និងពិន្ទុពីគ្រូ។

**សំណួរនិងចម្លើយដែលបានសួរញឹកញាប់ជាងគេអំពីការវិលត្រឡប់ទៅរៀននៅសាលាផ្ទាល់ជាមួយគ្រូវិញ**

**តើវិធានការអ្វីខ្លះសម្រាប់សុខភាពនិងសុវត្ថិភាពដែលអ្នកបានរៀបចំសម្រាប់ពេលសិស្សវិលត្រឡប់ទៅរៀនផ្ទាល់ជាមួយគ្រូវិញ?**

សុខភាពនិងសុវត្ថិភាពរបស់សិស្ស បុគ្គលិក និងគ្រួសាររបស់យើងគឺសំខាន់បំផុត។ សាលារៀននឹងមានសភាពខុសគ្នាឆ្ងាយពីឆ្នាំមុនដោយសារវិធានការសុខភាពនិងសុវត្ថិភាពថ្មី។ ផែនការបច្ចុប្បន្នសម្រាប់ការបើកទ្វារសាលាវិញគឺអាស្រ័យទៅលើការណែនាំពីមន្ត្រីសុខភាពសាធារណៈជននិងអង្គការនានារបស់រដ្ឋហើយនឹងធ្វើបច្ចុប្បន្នភាពទៅតាមកាលៈទេសៈ។ ឧទាហរណ៍ពីវិធានការសុខភាពនិងសុវត្ថិភាពគឺមានដូចជាការតម្រូវឱ្យបុគ្គលិកសាលានិងសិស្សពាក់ម៉ាស ការឆែកពិនិត្យមើលសុខភាព ការសំអាតនិងសម្លាប់មេរោគញឹកញាប់ និងការនៅឃ្លាតឆ្ងាយពីគ្នា។

**កូនខ្ញុំចុះឈ្មោះរៀនក្នុងកម្មវិធី GATE ។ បើយើងជ្រើសរើសកម្មវិធីអនឡាញពេញមួយឆ្នាំ តើកូនខ្ញុំនឹងមានគ្រូដដែលទេ?**

នៅពេលណាសិស្សអាចត្រឡប់ទៅរៀននៅសាលាវិញដោយសុវត្ថិភាព វានឹងមានការចែករំលែកសិស្សនិងគ្រូដើម្បីតម្រូវទៅតាមសំណើររបស់មាតាបិតាសម្រាប់ការរៀនតាមអនឡាញទល់នឹងជំរើសរៀនជាមួយគ្រូផ្ទាល់នៅសាលា។ កម្មវិធីរៀនតាមអនឡាញនឹងបង្រៀនដោយគ្រូដែលបានទទួលការហ្វឹកហ្វឺនឱ្យបង្រៀនក្នុងកម្មវិធី GATE ។

**តើមានការណែនាំអ្វីខ្លះពីមន្ត្រីសុខភាពក្នុងតំបន់ស្តីពីការអាចបើកសាលារៀនវិញ?**

រដ្ឋកាលីហ្វ័រនីញ៉ាបានកំណត់មកថាសាលានិងក្រសួងអប់រំអាចបើកសាលារៀនវិញសម្រាប់រៀនផ្ទាល់ជាមួយគ្រូបានបើសិនជាសាលានោះស្ថិតនៅក្នុងការត្រួតត្រារបស់ក្រសួងសុខាភិបាលក្នុងតំបន់ ដែលមិននៅក្រោមការតាមដានពិនិត្យមើលដោយខោនធីក្នុងអំឡុងរយៈពេល១៤ថ្ងៃមុនកន្លងមក។